**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

# សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាល
# ស្តីពី
# ការពង្រឹងការតាមដាន និងវិធានការឆ្លើយតបទៅនឹងករណីជំងឺរលាកសួតដោយវីរុសកូរ៉ូណាថ្មី (COVID-19) នៅកម្ពុជា

ក្រសួងសុខាភិបាល នៃព្រះរាជាណាចក្រកម្ពុជាបានទទួលព័ត៌មានពីក្រសួងសុខាភិបាលប្រទេសម៉ាឡេស៊ីថា មានករណីវីរុសកូរ៉ូណាថ្មី (COVID-19) ត្រូវបានរកឃើញលើអ្នកទេសចរម្នាក់ដែលបានធ្វើដំណើរតាមនាវា វេស្ទឺដាម (Holland America MS Westerdam) នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២០។

ករណីវីរុសកូរ៉ូណាថ្មី (COVID-19) នេះបានកើតលើស្ត្រីជនជាតិអាមេរិចកាំង មានអាយុ ៨៣ ឆ្នាំ និងបច្ចុប្បន្នកំពុងស្ថិតនៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី។

គាត់បានធ្វើដំណើរឆ្ពោះទៅសហរដ្ឋអាមេរិក ពីក្រុងព្រះសីហនុប្រទេសកម្ពុជា កាត់តាមទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី។ គាត់ជាអ្នកដំណើរម្នាក់ក្នុងចំណោមអ្នកដំណើរ ២២៥៧ នាក់ នៅលើនាវាវេស្ទឺដាម ដែលបានចូលសំចតនៅកំពង់ផែខេត្តព្រះសីហនុ ប្រទេសកម្ពុជា នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០។

ឯកឧត្តមសាស្ត្រាចារ្យ **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាប្រធានក្រុមការងារឆ្លើយតបការរាតត្បាតនៃវីរុសកូរ៉ូណាថ្មី (COVID-19) បានកោះប្រជុំជាបន្ទាន់នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២០ នៅទីស្តីការក្រសួងសុខាភិបាល ហើយក្រុមការងារបានឯកភាពលើវិធានការណ៍សុខភាពសាធារណៈដូចខាងក្រោម៖

- ធ្វើការពិនិត្យសុខភាពអ្នកដំណើរលើនាវាខ្នាតធំវេស្ទឺដាមទាំងអស់នៅភ្នំពេញ និងនៅក្រុងព្រះសីហនុដើម្បីពិនិត្យរកមើលរោគសញ្ញាណាមួយដែលកើតឡើង។
- រាល់បុគ្គលដែលធ្វើដំណើរលើនាវាវេស្ទឺដាម ត្រូវបន្តតាមដានសុខភាពរបស់ខ្លួនឲ្យបានហ្មត់ចត់។ បុគ្គលដែលមានរោគសញ្ញាដូចជា ក្តៅខ្លួន ក្អក ឬពិបាកដកដង្ហើម ត្រូវផ្តល់ព័ត៌មានទៅកាន់អាជ្ញាធរសុខាភិបាលក្នុងស្រុក និងប្រាប់ពីប្រវត្តិធ្វើដំណើរ។

បន្ថែមលើនេះ ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ធ្វើតេស្តដោយមន្ទីរពិសោធន៍វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា លើអ្នកដំណើរដោយនាវាវេស្ទឺដាមដែលនៅសេសសល់កំពុងស្នាក់នៅក្នុងប្រទេសកម្ពុជា។

បន្ទាប់ពីជាប់គាំងរយៈពេលប៉ុន្មានថ្ងៃក្នុងសមុទ្រដែលប្រទេសចំនួន០៥ បដិសេធន៍មិនឱ្យចូលចត ប្រមុខ រាជរដ្ឋាភិបាលកម្ពុជា បានយល់ព្រមទទួលសំណើសុំចូលចតរបស់នាវាវេស្ទើដាម ដែលមានមនុស្ស ចំនួន ២២៥៧នាក់ (៤១ សញ្ជាតិ) នៅលើនាវា ដោយយោងលើកត្តាចាំបាច់នៃការស្រោចស្រង់អាយុជីវិត មនុស្សធម៌ សាមគ្គីភាព និងតម្រូវការផ្សេងៗរបស់អ្នកធ្វើដំណើរ ។

ក្រោយពីនាវាចូលសំចត នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេច អនុញ្ញាតឲ្យអ្នកធ្វើដំណើរចុះពីនាវា ដោយផ្អែកលើ ៖

- ទម្រង់ប្រកាសសុខភាពរបស់នាវា ដែលអាជ្ញាធរកំពង់ផែបានទទួល បញ្ជាក់ថាមានបុគ្គលចំនួន ១៨រូប លើនាវាមានបញ្ហាសុខភាពក្នុងរយៈពេលធ្វើដំណើរ។ ទម្រង់ប្រកាសសុខភាពដែល ចេញដោយក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានប្រមូលពីអ្នកដំណើរ និង នាវិកទាំងអស់។ សំណាកពីច្រមុះ និងបំពង់ក ត្រូវបានប្រមូលពីបុគ្គល ២០រូប ដែលបាន រាយការណ៍ថាមានរោគសញ្ញាស្រដៀងផ្តាសាយ ឬរាគរូស នៅពេលយកសំណាកឬក្នុងពេល ធ្វើដំណើរ។ សំណាកត្រូវបានបញ្ជូនទៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជាដើម្បីធ្វើតេស្តរកវីរុសកូរ៉ូណាថ្មី (COVID-19)។ សំណាកទាំងអស់មានលទ្ធផលតេស្តអវិជ្ជមាន។
- មុនពេលការចុះនាវា ក្រុមការងារក្រសួងសុខាភិបាល និងមន្ទីរសុខាភិបាលខេត្តព្រះសីហនុបាន ត្រួតពិនិត្យសីតុណ្ហភាពលើបុគ្គលទាំងអស់លើនាវា ហើយមិនបានរកឃើញថាមានគ្រុនក្តៅទេ។

នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ មនុស្សចំនួន ៤០៩នាក់ បានចុះចេញពីនាវាខ្នាតធំវេស្ទើដាម ដោយធ្វើដំណើរតាមយន្តហោះចាកចេញពីអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ និងបន្តជើងហោះ ហើរនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ដើម្បីធ្វើដំណើរទៅកាន់ប្រទេសកំណើតរបស់ពួកគេ។ នៅថ្ងៃទី ១៥-១៦ ខែកុម្ភៈ ឆ្នាំ២០២០ មានអ្នកដំណើរចំនួន ៦០១នាក់ បន្ថែមទៀត ពីនាវាដដែលមកកាន់អាកាស យានដ្ឋានអន្តរជាតិភ្នំពេញ ដើម្បីរង់ចាំការចេញដំណើរបន្តទៅកាន់ប្រទេសពួកគេ។

អង្គការសុខភាពពិភពលោក (WHO) មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក (US CDC) និងស្ថានទូតពាក់ព័ន្ធនានាបានចូលរួមយ៉ាងសកម្មនៅក្រុងព្រះសីហនុក្នុងការគាំទ្ររដ្ឋាភិបាលកម្ពុជា ដើម្បី ឆ្លើយតបព្រឹត្តិការណ៍នេះ។

សូមបញ្ជាក់ថា ក្រសួងសុខាភិបាល បាននិងកំពុងអនុវត្តតាមនិយាមស្តង់ដារបច្ចេកទេស និង និយ័តកម្មអន្តរជាតិឆ្នាំ២០០៥ របស់អង្គការសុខភាពពិភពលោក រាល់ពេលប្រតិបត្តិការនៅលើនាវា និង នៅដីគោក ដោយមានកិច្ចសហការជិតស្និទ្ធពីអង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លង សហរដ្ឋអាមេរិក (US CDC) វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា និងអាជ្ញាធរពាក់ព័ន្ធ។

មកទល់នឹងពេលនេះ មិនមានប្រជាជនកម្ពុជាណាម្នាក់ដែលមានផ្ទុកវីរុស COVID-19 នោះទេ។

ក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក សូមធ្វើការណែនាំដល់សាធារណជន ទាំងអស់ ត្រូវអនុវត្តការប្រុងប្រយ័ត្ន និងធ្វើអនាម័យជាស្តង់ដារ ដើម្បីកាត់បន្ថយការប៉ះពាល់ និងការចម្លង ជំងឺមួយចំនួន។ ការប្រុងប្រយ័ត្នរួមមាន អនាម័យដៃជាប្រចាំ គ្របមាត់ និងច្រមុះនៅពេលក្អក និងកណ្តាស់

និងជៀសវាងការទាក់ទងជិតស្និទ្ធជាមួយអ្នកណាម្នាក់ដែលមាន រោគសញ្ញាផ្លូវដង្ហើមដូចជាក្អក និងកណ្តាស់ ជាដើម។ បើអ្នកគិតថា អាចមានប៉ះពាល់ជាមួយអ្នកមានវីរុសថ្មី ឬបានឆ្លងរោគនេះ ហើយមានគ្រុនក្តៅ ក្អក ឬពិបាកដកដង្ហើម ត្រូវស្វែងរកការព្យាបាលអោយបានឆាប់រហ័ស និងផ្តល់ព័ត៌មានអំពីប្រវត្តិធ្វើដំណើរពីមុនដល់មន្ត្រីដែលផ្តល់សេវាថែទាំសុខភាព។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវឌ្ឍនៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក របស់ក្រសួងសុខាភិបាល ទំព័រហ្វេសប៊ុក និងគេហទំព័ររបស់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកបាន។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬ ទំនាក់ទំនងក្រសួងសុខាភិបាល៖

- លោកវេជ្ជបណ្ឌិត លី សូវ៉ាន់ ៖០១២ ៨២៥ ៤២៤
- លោកវេជ្ជបណ្ឌិត យី សេងឌឿន ៖០១២ ៤៨៨ ៩៨១
- លោកស្រីវេជ្ជបណ្ឌិត គេង ស្រី ៖០១២ ៨៣៦ ៨៦៨

ថ្ងៃចន្ទ ៩រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០